# អត្ថប្រយោជន៍
# បន្ថែមការការពារ



## កម្មវត្ថុនៃការធានារ៉ាប់រង

អាយុជីវិតនៃអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រង។

## លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុអ្នកត្រូវបានធានារ៉ាប់រង | 1 - 60ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 5 - 30ឆ្នាំ |
| ទឹកប្រាក់ត្រូវបានធានា | ចាប់ពី $5,000 ឡើង |

## លក្ខខណ្ឌនៃការបង់បុព្វលាភ

| | |
|---|---|
| វិធីសាស្ត្របង់បុព្វលាភ | ប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស ប្រចាំខែ |
| មធ្យោបាយបង់បុព្វលាភ | ការផ្ទេរប្រាក់តាម App ឬគណនីធនាគារ សាច់ប្រាក់ មូលប្បទានបត្រ |
| ការបំពាន | បន្ទាប់ពីការបង់បុព្វលាភធានារ៉ាប់រងលើកទី ១ (មួយ) ការខកខានក្នុងការបង់បុព្វលាភធានារ៉ាប់រងបន្តបន្ទាប់នៅកាលបរិច្ឆេទដល់កាលកំណត់បង់នឹងត្រូវបានចាត់ទុកជាការបំពានលក្ខខណ្ឌបង់បុព្វលាភធានារ៉ាប់រង។ ប្រសិនបើបុព្វលាភធានារ៉ាប់រងនៅតែមិនទាន់បានបង់បន្ទាប់ពីរយៈពេលអនុគ្រោះ (30ថ្ងៃ) ដល់កាលកំណត់ បណ្ណសន្យារ៉ាប់រងនឹងត្រូវផ្អាកសុពលភាព គិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃផុតកំណត់នៃរយៈពេលអនុគ្រោះ ហើយបណ្ណសន្យារ៉ាប់រងនេះនឹងមិនមានសុពលភាពក្នុងអំឡុងពេលនៃការផ្អាកសុពលភាពនេះឡើយ។ |

## វិសាលភាពនៃការធានារ៉ាប់រង

ផលិតផលនេះផ្តល់ការការពារលើ មរណភាព ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ និងការរះកាត់/ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ ក្នុងអំឡុងពេលដែលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព។

# អត្ថប្រយោជន៍ធានារ៉ាប់រង

## ជម្រើសទី១

ករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍

ម្ចាស់បណ្ណសន្យារ៉ាប់រង

អ្នកត្រូវបានធានារ៉ាប់រង

១០០% នៃទឹកប្រាក់ត្រូវបានធានានឹងត្រូវផ្ដល់ជូន ក្នុងករណីម្ចាស់បណ្ណសន្យារ៉ាប់រង និង/ឬ អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។

## ជម្រើសទី២

ករណីមរណភាព ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់

ម្ចាស់បណ្ណសន្យារ៉ាប់រង

អ្នកត្រូវបានធានារ៉ាប់រង

១០០% នៃទឹកប្រាក់ត្រូវបានធានានឹងត្រូវផ្ដល់ជូន ក្នុងករណីម្ចាស់បណ្ណសន្យារ៉ាប់រង និង/ឬ អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬធ្វើរោគវិនិច្ឆ័យរកឃើញ/ការវះកាត់ ជាក់ស្ដែងនូវជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់ណាមួយដូចបាន ចែងក្នុងខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រង។

# ករណីមិនធានា

**១. មរណភាព**

មិនមានអត្ថប្រយោជន៍លើមរណភាពនឹងត្រូវផ្តល់ជូននោះទេ ប្រសិនបើមរណភាពរបស់អ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រង ត្រូវបានបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖

(១) ការធ្វើអត្តឃាតក្នុងរយៈពេល ២ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ។

(២) ការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

(៣) វីរុសហ៊ីវ (HIV) និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ (HIV) ដែលរួមមានទាំងជំងឺអេដស៍ និង/ឬការបំលែង ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍។

(៤) ការប្រើប្រាស់ថ្នាំញៀន ឬថ្នាំភ្លេចអារម្មណ៍ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬផលវិបាកផ្សេងៗដូចដែលបានកំណត់ដោយច្បាប់ដែលបានចូលជាធរមាន។

**២. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**

ក្រុមហ៊ុនមិនធានាលើការបាត់បង់ ឬពិការភាពដែលបណ្តាលមកពីព្រឹត្តិការណ៍ដែលកើតឡើងដោយផ្ទាល់ឬដោយប្រយោល ទាំងស្រុង ឬ ដោយផ្នែក ដោយសារព្រឹត្តិការណ៍ណាមួយដូចខាងក្រោម៖

(១) ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

(២) ការឆ្លងវីរុសហ៊ីវ (HIV) រោគសញ្ញានៃជំងឺអេដស៍ ឬជំងឺដែលទាក់ទងនឹងជំងឺអេដស៍។

(៣) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) ការឈ្លានពាន សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ចលាចលស៊ីវិល ការធ្វើកុបកម្ម ការធ្វើកូដកម្ម ការបះបោរប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។

(៤) ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងប្រព្រឹត្តបទឧក្រិដ្ឋ ឬខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងកំពុងត្រូវបានចាប់ខ្លួន ឬត្រូវរងការចាប់ខ្លួន ឬកំពុងរត់គេចពីការចាប់ខ្លួន។

(៥) ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការបញ្ជា ការធ្វើប្រតិបត្តិការជួសជុលថែទាំ ឬត្រូវបានដឹកជញ្ជូនដោយយានឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាសនានា លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយ ដែលធ្វើប្រតិបត្តិការជាទៀងទាត់តាមកាលវិភាគ និងតាមគន្លងផ្លូវដឹកជញ្ជូនអ្នកដំណើរផ្លូវអាកាសដែលបានកំណត់ជាមុនរបស់ក្រុមហ៊ុន។

(៦) ខណៈពេលដែលអ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងបំពេញកាតព្វកិច្ចជាយោធា ប៉ូលីស ឬជាអ្នកស្ម័គ្រចិត្តចូលរួមក្នុងសង្គ្រាម ឬការបង្ក្រាបឧក្រិដ្ឋកម្ម។

(៧) ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងបានដឹងច្បាស់លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុននិងទទួលយកដោយក្រុមហ៊ុន។ អ្នកត្រូវបានធានារ៉ាប់រង និង/ឬម្ចាស់បណ្ណសន្យារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមាន ពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម៖

- ក) អ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងបានទទួល ឬកំពុងទទួលការព្យាបាល
- ខ) យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ
- គ) មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ ឬ
- ឃ) វត្តមាននៃស្ថានភាពនោះអាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈណាមួយ។

(៨) អ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។
(៩) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។

**៣. ការរះកាត់/ជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់**

(១) ជំងឺដែលបណ្តាលមកពីជំងឺអេដស៍ ភាពស្មុគស្មាញទាក់ទងនឹងជំងឺអេដស៍ ឬការបង្ករោគដោយវីរុសហ៊ីវ (HIV)។
(២) ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទដែលអត្ថប្រយោជន៍ធានារ៉ាប់រងបន្ថែមនេះមានសុពលភាព ឬកាលបរិច្ឆេទនៃការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។ អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងអាចត្រូវបានចាត់ទុកថាបានដឹងច្បាស់អំពីស្ថានភាពដែលមានពីមុនស្រាប់ ប្រសិនបើមានស្ថានភាពណាមួយដូចបានចែងខាងក្រោម៖
ក. អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងបានទទួល ឬកំពុងទទួលការព្យាបាល
ខ. យោបល់វេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ឬការព្យាបាលផ្នែកវេជ្ជសាស្ត្រត្រូវបានណែនាំ
គ. មានរោគសញ្ញាច្បាស់ និងជាក់លាក់ត្រូវបានបង្ហាញ
ឃ. វត្តមាននៃស្ថានភាពនោះអាចមើលឃើញដោយបុគ្គលធម្មតាក្នុងកាលៈទេសៈណាមួយ។
(៣) ការប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។
(៤) អ្នកត្រូវបានធានារ៉ាប់រង និង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណត្រឹមត្រូវ។
(៥) ជំងឺធ្ងន់ធ្ងរទាំងអស់ដែលមានស្រាប់ ឬធ្វើរោគវិនិច្ឆ័យរកឃើញក្នុងរយៈពេលរង់ចាំដោយរាប់បញ្ចូលទាំងជំងឺធ្ងន់ធ្ងរកម្រិតដំបូង ដែលត្រូវបានរកឃើញពេលធ្វើរោគវិនិច្ឆ័យដំបូងក្នុងរយៈពេលរង់ចាំ ហើយវិវត្តទៅជាជំងឺធ្ងន់ធ្ងរកម្រិតធ្ងន់បន្ទាប់ពីរយៈពេលរង់ចាំត្រូវបានផុតកំណត់។
(៦) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) ការឈ្លានពាន សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ចលាចលស៊ីវិល ការធ្វើកុបកម្ម ការធ្វើកូដកម្ម ការបះបោរប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។
(៧) ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដោយម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល។ អ្នកទទួលផលដែលមិនបានចូលរួមពាក់ព័ន្ធក្នុងសកម្មភាពបទល្មើសព្រហ្មទណ្ឌដែលបានរៀបរាប់ខាងលើ នឹងនៅតែមានសិទ្ធិទទួលបានអត្ថប្រយោជន៍របស់ពួកគេដដែល។
(៨) ប្រសិនបើមានផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលពីការសារធាតុវិទ្យុសកម្មដែលកើតឡើងពីឥន្ទនៈ អាវុធ កាកសំណល់ ឬការកែច្នៃ។
(៩) ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការបញ្ជា ការធ្វើប្រតិបត្តិការជួសជុលថែទាំ ឬត្រូវបានដឹកជញ្ជូនដោយយានឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាសនានា លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងនិង/ឬ ម្ចាស់បណ្ណសន្យារ៉ាប់រងគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយ ដែលធ្វើប្រតិបត្តិការជាទៀងទាត់តាមកាលវិភាគ និងតាមគន្លងផ្លូវដឹកជញ្ជូនអ្នកដំណើរផ្លូវអាកាសដែលបានកំណត់ជាមុនរបស់ក្រុមហ៊ុន។
(១០) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។

ចំណាំ៖ ខ្លឹមសារក្នុងខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិតនៃការធានារ៉ាប់រង រួមមានអត្ថប្រយោជន៍ធានារ៉ាប់រង ករណីមិនធានា និងលក្ខខណ្ឌនៃការបញ្ចប់កិច្ចសន្យា សូមអានខ និងលក្ខខណ្ឌធានារ៉ាប់រង។